00204546

C22/I/62

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំនុំរឿងលេខ** | ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) |
| **ប្ដឹងទៅ** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទឯកសារ** | ១៧ កក្កដា ២០០៨ |
| **ភាគីប្ដឹង** | ដើមបណ្ដឹងរដ្ឋប្បវេណី |
| **ភាសា** | ខ្មែរ និង អង់គ្លេស |
| **ប្រភេទឯកសារ** | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2008
ម៉ោង (Time/Heure): 14 : 55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ពាក្យស្នើសុំសេចក្ដីប្រកាសជាប្រយោជន៍ (Declarative Relief) សំរាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់, មិនមែនស្នើសុំសំរាប់ការបើកសវនាការឡើងវិញនោះទេ

ប្ដឹងដោយ :

**ដើមបណ្ដឹងរដ្ឋប្បវេណី**

ធារី ចាន់សេង

ផ្ញើជូន :

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

យ៉េត ចរិយា

William SMITH

Anees AHMED

**សហមេធាវីលោកអៀង សារី**

អាង ឧត្ដម

Michael KARNAVA

ប្ដឹងទៅ :

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៍យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ហុង គឹមសួន

គង់ ពិសី

ឡោ ជុនឌី

នី ចាន់ឌី

Silke STUDZINSKY

យុង ផានិត

**អង្គភាពគាំទ្រជនរងគ្រោះ**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

00204547

C22/I/62

**សហមេធាវីលោកកាំង ហ្គិចអៀវ**

កា សាវុធ

Francois Roux

**សហមេធាវីលោកខៀវ សំផន**

សាយ បូរី

Jacques Verges

គាត បូផល

Gabriela GONZALEX RIVAS

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង

Marcel LEMONDE

**សហមេធាវីលោកស្រីអៀង ធីរិទ្ធ**

ផាត់ ពៅសៀង

Diana Ellis

00204548

C22/I/62

## I. សេចក្តីសង្ខេប

១. នៅថ្ងៃទី៨ កក្កដា ២០០៨, អង្គបុរេជំនុំជម្រះ («**អបជ**»)បានចេញសេចក្តីប្រកាសអំពី «សេចក្តីណែនាំចំពោះភាគីពាក់ព័ន្ធទាក់ទងទៅនឹងពាក្យសុំឱ្យពិចារណាឡើងវិញ អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ» («សេចក្តីណែនាំអំពីការសុំឱ្យពិចារណាឡើងវិញ) ដែលបានបញ្ជាក់ថា ពាក្យសុំឱ្យ ពិចារណាឡើងវិញរបស់នាងខ្ញុំ «នៅដំណាក់កាលនេះ ពាក្យសុំនេះគួរត្រូវបានបកស្រាយថា ជាសំណើសុំឱ្យបើកសវនាការជាថ្មី ដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីថ្លែងប្រាស្រ័យ»។

២. នាងខ្ញុំឈ្មោះ សេង ធារី ដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណី («**អ្នកដាក់ពាក្យស្នើសុំ**») មានបំណងចង់ធ្វើការបញ្ជាក់អះអាងថា នាងខ្ញុំមិនមែនកំពុងស្វះស្វែងសុំឱ្យមានការបើកសវនាការជាថ្មីឡើងវិញនោះទេ ប៉ុន្តែនាងខ្ញុំសូមសំណូមពរឱ្យមាន សេចក្តីប្រកាសជាប្រយោជន៍ (Declarative Relief)។ វាជាការពិតណាស់ ដែលថា ការបើកសវនាការ ឡើងវិញនឹងជួសជុលការខូចខាត ចំពោះការណ៍ដែលថា ភាពពាក់ព័ន្ធរបស់នាងខ្ញុំក្នុងនាមជាភាគី[1] មួយ នៅក្នុងនីតិវិធីព្រហ្មទណ្ឌអង្គបុរេជំនុំជម្រះករណីលោកអៀង សារី មិនត្រូវបានតំណាងដោយរូបនាង វីមេធារី របស់នាង។ ក៏ប៉ុន្តែ ដោយស្របទៅតាម «*ផលប្រយោជន៍របស់ អបជ ក្នុងការធានាឱ្យបាននូវដំណើរការ ឆាប់រហ័ស*» ហើយដោយសារថាសវនាការនេះ បានបញ្ចប់រួចទៅហើយនោះ ដូចនេះការ បើកសវនាការ ឡើងវិញសំរាប់ករណីនេះ វានឹងបង្កឱ្យមានការប្រើប្រាស់ ដោយពុំមានប្រសិទ្ធភាពនូវ ពេលវេលា ថាមពល និងធនធាន ទេវិញទេ។ ដូច្នេះ អ្នកដាក់ពាក្យស្នើសុំ សូមសំណូមពរឱ្យមានសំណងក្នុងទំរង់ជា សេចក្តីប្រកាសជាប្រយោជន៍ Declarative Relief វិញ។

## II. អង្គហេតុ

៣. កាលពីថ្ងៃទី ២៥ កញ្ញា ២០០៧, ភាគីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ពាក្យស្នើសុំផ្ទាល់ខ្លួនមួយ ដែលត្រូវបានទទួលដោយ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត («**កសចស**») នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («**អ.វ.ត.ក**»)។ ពាក្យស្នើសុំនោះ ត្រូវបានដាក់ចូលទៅក្នុង ករណីសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស នៅក្នុងថ្ងៃដដែលនោះ[2]។

---

[1] វិធានផ្ទៃក្នុង ២៣(៦)(ក) : «នៅពេលដែលបានចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីហើយ ជនរងគ្រោះរូបនោះនឹងក្លាយទៅជា ភាគី មួយនៅក្នុងនីតិវិធីព្រហ្មទណ្ឌនេះ»។

[2] ស្ថានភាពនៃការធ្វើញត្តិ របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃ២០ វិច្ឆិកា ២០០៧។ គួរកត់សំគាល់ថាឯកសារដើម ត្រូវបានទទួលនៅថ្ងៃ២០ វិច្ឆិកា ២០០៧ នៅវេលាម៉ោង ២ រសៀល ដោយ នប់ សុធនវិចិត្រ, ដែលជាមន្ត្រីស្តីទីទទួលបន្ទុកផ្នែកសំណុំរឿង (គឺមួយថ្ងៃបន្ទាប់ពីការចាប់ខ្លួននិងការឃុំខ្លួនលោក នួន ជា, ថ្ងៃ១៩ កញ្ញា)។

៤. នៅថ្ងៃទី២៨ ធ្នូ ២០០៧, អ្នកដាក់ពាក្យស្នើសុំ ត្រូវបាន ងរថេថិរេស នៃ កសចស ជូនដំណឹងតាមរយៈ អាស័យដ្ឋានអ៊ីមែល នៅលើពាក្យស្នើសុំនោះ ស្តីពីសវនាការឃុំខ្លួនបណ្តោះអាសន្នទៅលើលោក នួន ជា នៅក្នុង អបជ ដែលត្រូវគ្រោងធ្វើនៅថ្ងៃទី០៤ កុម្ភៈ ២០០៨។

៥. នៅថ្ងៃទី ៣១ មករា ២០០៨, សហចៅក្រមស៊ើបអង្កេត គឺលោក យូ ប៊ុនឡេង និងលោក Marcel LEMONDE បានទទួលស្គាល់លោក នី ចាន់ឌី អ្នកតំណាងស្របច្បាប់របស់ **អ្នកដាក់ពាក្យស្នើសុំ**។ នៅក្នុងឯកសារចុះថ្ងៃទី ៣០ មករា ២០០៨, អ្នកដាក់ពាក្យសុំបាន (១)រក្សាសិទ្ធិរបស់នាងយ៉ាងដាច់ខាត *«ក្នុងការតំណាងរូបនាងខ្ញុំដោយផ្ទាល់ រឺ / និង មានមេធាវីសំរាប់តំណាងនាងខ្ញុំនៅគ្រប់ដំណាក់កាលទាំងអស់ ... ជាពិសេសនៅក្នុងអង្គបុរេជំនុំជម្រះ»*, និង (២) បានបញ្ជាក់ពីគោលបំណងចង់ *«ក្លាយទៅជាអ្នកតំណាងសំរាប់ជនរងគ្រោះដែលក្លាយជាជនកំព្រាកំឡុងរបបខ្មែរក្រហម»* ។

៦. មុនការបើកសវនាការដែលគេកំណត់ឡើងវិញនៅថ្ងៃទី ០៧ កុម្ភៈ ២០០៨, កំណែថ្មីនៃ «ក្រមសីលធម៌ និតិវិធីព្រហ្មទណ្ឌ» ត្រូវបានគេចាកជូនទៅដល់ភាគីទាំងឡាយ ដោយមានបង្ហាញពីឈ្មោះមេធាវីបួននាក់សំរាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបួននាក់នៅពេលនោះ ដោយបញ្ជាក់ថាពួកគេត្រូវបានអនុញ្ញាតិឱ្យធ្វើសេចក្តីថ្លែងផ្ទាល់មាត់រហូតដល់ទៅសាមសិបនាទីក្នុងម្នាក់ៗ។

៧. អ្នកដាក់ពាក្យស្នើសុំ បានធ្វើការថ្លែងប្រាស្រ័យនៅចំពោះមុខ អបជ លើកដំបូងនៅថ្ងៃទី ០៨ កុម្ភៈ ២០០៨ នៅពេលចាប់ផ្តើមដំបូងនាថ្ងៃទីពីរនៃការធ្វើសវនាការស្តីពីការឃុំខ្លួនបណ្តោះអាសន្ន។ នៅក្នុងឱកាសនេះ អ្នកដាក់ពាក្យសុំបានថ្លែងប្រាស្រ័យអស់រយៈពេលម្ភៃនាទីក្នុងចំណោមពេលវេលាសាមសិបនាទីដែលផ្តល់ដល់នាង និងមេធាវីរបស់នាង។ បន្ទាប់ពីនោះមក ការថ្លែងប្រាស្រ័យនោះ ត្រូវបានគេអបអរសាទរថាជា «ប្រវត្តិសាស្រ្ត» និង «មិនធ្លាប់មានពីមុនមក» នៅក្នុងប្រវត្តិសាស្រ្តច្បាប់អន្តរជាតិ និងសាលាក្តីអន្តរជាតិ ពីសំណាក់អ្នកសង្កេតការណ៍ទាំងជាតិ និងអន្តរជាតិ, ដែលជាពាក្យសំដីដកស្រង់ចេញពី លោកស្រីបណ្ឌិត ហេឡែន ចារីស, លោក ភីធី ហ្មុសស្ទី និងលោក រាជ សម្បត្តិ នៃផ្នែកកិច្ចការសាធារណៈ។

៨. នៅក្នុងសុន្ទរកថារបស់នាង, អ្នកដាក់ពាក្យស្នើសុំបានទទួលស្គាល់ថា ការអនុញ្ញាតិឱ្យ ជនរងគ្រោះបានចូលរួមដោយផ្ទាល់ជាភាគីនេះអាចធ្វើឱ្យមាន «ភាពស្មុគស្មាញផ្នែករដ្ឋបាល», ប៉ុន្តែនាងក៏បានបញ្ជាក់ផងដែរថា *«ទោះបីជាមានហានិភ័យបែបនេះក៏ដោយ ក៏ការចូលរួមរបស់ជនរងគ្រោះ បានឆ្លុះបញ្ចាំងពីទំនុកចិត្ត និងជំនឿរបស់តុលាការ ទៅលើជនរងគ្រោះ ថាផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានគេរាប់បញ្ចូល ហើយសំឡេងរបស់ជនរងគ្រោះមានគេស្តាប់លឺ»*។ បន្ទាប់មក អ្នកដាក់ពាក្យស្នើសុំក៏បានបន្តប្រកាសថា ជនរងគ្រោះ រឺភាគី

ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែ *«ការពារទំនុកចិត្តនិងការជឿជាក់របស់ពួកយើងនៅក្នុងដំណើរការនេះ»* ហើយត្រូវយល់ថា តុលាការត្រូវរក្សាសណ្ដាប់ធ្នាប់ និងភាពសមរម្យថ្លៃថ្នូរ។ នីតិរដ្ឋ និងសិទ្ធិរបស់ជនត្រូវចោទ ត្រូវតែទទួលបានការគោរព។ អ្នកដាក់ពាក្យស្នើសុំ ក៏បានសង្កត់ធ្ងន់ថា នាងកំពុងតែថ្លែងប្រាស្រ័យនៅចំពោះមុខ អបជ ក្នុងនាមជា ជនរងគ្រោះ រឺភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសមត្ថភាពពីរយ៉ាង : ទីមួយក្នុងនាមជាពលរដ្ឋឯកជន និងទីពីរ *«ក្នុងនាមជាអ្នកតំណាងឱ្យជនរងគ្រោះទូទៅដែលមិនមានសំឡេង ... គឺក្រុមអ្នកកំព្រា»*។

៩. អ្នកដាក់ពាក្យស្នើសុំ បានចំណាយពេលប្រហែលពាក់កណ្ដាលនៃពេលវេលាដែលគេបានកំណត់ឱ្យ ដើម្បីធ្វើការសង្កត់បញ្ជាក់ពីចំណុចខាងដើម មុនពេលធ្វើសេចក្ដីសំអាងថាហេតុអ្វីបានជានាងជឿជាក់ថាការឃុំខ្លួនលោក នួន ជា បណ្ដោះអាសន្នគឺជារឿងត្រឹមត្រូវ។

១០. ឱកាសលើកទីពីរសំរាប់អ្នកដាក់ពាក្យស្នើសុំក្នុងការថ្លែងប្រាស្រ័យនៅចំពោះមុខ អបជ កើតមានឡើងនៅក្នុងសវនាការឃុំខ្លួនបណ្ដោះអាសន្នករណីលោក ខៀវ សំផន *ដោយមានការថតជាវីដេអូ* កាលពីថ្ងៃទី ២៣ មេសា ២០០៨ (គឺបន្ទាប់ពីករណីលោក នួន ជា)។ ចំពោះ អំណះអំណាងរបស់មេធាវីការពារក្ដី គឺលោក ហ្សាក់ វើសេស (Jacque VERGERS) ដែលថាគាត់មិនអាចការពារក្ដីរបស់គាត់បានទេដរាបណាឯកសាររបស់ អវតក ទាំងអស់មិនទាន់បានបកប្រែជាភាសាបារាំងចប់ទេនោះ, អ្នកដាក់ពាក្យស្នើសុំ បានឆ្លើយតបដោយផ្ទាល់ចំពោះអំណះអំណាងនោះទេវិញថា *«លោកខៀវ សំផន, លោកមានមេធាវីជាជនជាតិខ្មែរនិងបរទេស ដូច្នេះ នេះគឺជាសារសំខាន់ជាមូលដ្ឋាន ដែលលោកមិនត្រូវភ្លេចនូវគោលការណ៍ខាងក្រោមនេះទេថា : យើងមិនត្រូវ អនុញ្ញាតិអោយភាពល្អឥតខ្ចោះ ក្លាយទៅជាសត្រូវនៃភាពល្អនោះទេ គឺថាយើងត្រូវតែមានហេតុផល ហើយយើងត្រូវតែប្រើប្រាស់សុភវិនិច្ឆ័យរបស់យើង»*។ បន្ទាប់ពីបញ្ជាក់ជាភាសាខ្មែរ អ្នកដាក់ពាក្យស្នើសុំ ក៏បានបញ្ជាក់ពីគោលការណ៍នេះឡើងវិញជាភាសាអង់គ្លេស រួចហើយបានអង្គុយចុះ។

១១. នៅក្នុងឱកាសទាំងពីរលើកនោះ ទាំងតុលាការ និងភាគីទាំងអស់បានទទួលស្គាល់និងយល់ព្រមឱ្យ អ្នកដាក់ពាក្យសុំថ្លែងប្រាស្រ័យទៅកាន់តុលាការដោយផ្ទាល់។ ជាពិសេស គេគួរតែរំលឹកឡើងវិញថា (១) នៅក្នុងឱកាសលើកទីមួយ ការិយាល័យកិច្ចការសាធារណៈ របស់ អវតក ទទួលស្គាល់ថាវាមានលក្ខណៈប្រវត្តិសាស្ត្រ និងមិនធ្លាប់មានពីមុនមក, ហើយ (២) នៅក្នុងឱកាសលើកទីពីរ, មេធាវីរបស់លោក ខៀវ សំផន មានប្រតិកម្មដោយការភ្ញាក់ផ្អើលនៅពេលដែលតុលាការសួរ ថាតើពួកគេជំទាស់ចំពោះ ភាគីដើម បណ្ដឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យ ដោយផ្ទាល់នៅចំពោះមុខ អបជ ដែររឺទេ។ ពួកគេយល់និងព្រម ទទួលថាសិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យចំពោះមុខ អបជ គឺមាន ក្នុងមានជាភាគី ដែលមានការ

ទទួលស្គាល់ចំពោះដំណើរការរឿងក្តី ហើយបានសួរថា "តើបញ្ហានេះមិនទាន់បានសំរេចនៅក្នុង សវនាការករណីលោក នួន ជា ទេរឺ?"[៣]

១២. គួរចងចាំថានៅក្នុងឱកាសទាំងពីរដែលអ្នកដាក់ពាក្យស្នើសុំបានថ្លែងប្រាស្រ័យដោយផ្ទាល់ទៅកាន់ អបជ រូបគាត់មានការតំណាងស្របច្បាប់ដែលមានវត្តមាននៅក្នុងតុលាការ។

១៣. អ្នកដាក់ពាក្យស្នើសុំមិនអាចចូលរួមសវនាការឃុំខ្លួនបណ្តោះអាសន្នករណីលោកស្រី អៀង ធារិទ្ធ កាលពីថ្ងៃទ ២១ ឧសភា ២០០៨ដោយផ្ទាល់ទេ ប៉ុន្តែរូបគាត់ត្រូវបានតំណាងដោយមេធាវីរបស់ខ្លួនដែរ។ រយៈពេលមុននេះមួយថ្ងៃ គឺនៅថ្ងៃទី ២០ ឧសភា ២០០៨ អបជ បានចេញសេចក្តីណែនាំ ថាការថ្លែងសេចក្តីផ្ទាល់មាត់ជួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ៧៧ (១០) នឹងត្រូវធ្វើឡើងដោយមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ("សេចក្តីណែនាំអំពីការថ្លែងសេចក្តី ផ្ទាល់មាត់")[៤] ។

១៤. សវនាការបន្ទាប់មកទៀតដែលអ្នកដាក់ពាក្យសុំបានចូលរួមនោះ គឺនៅថ្ងៃទី៣០ មិថុនា ២០០៨ អំពីករណីលោក អៀង សារី។ នៅថ្ងៃទី០១ កក្កដា ២០០៨ អបជ បានចេញសេចក្តីសំរេចមួយអំពីបញ្ហា ដំបូងដែលបានលើកឡើងដោយ សហមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី ដោយច្រានចោលសំណើដែលសុំឱ្យមានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ *"បានថ្លែងប្រាស្រ័យដោយផ្ទាល់ទោះបីជា មានមេធាវីការពារក៏ដោយ"*[៥] (**"សេចក្តីសំរេចស្តីពីបញ្ហាដំបូង"**)។ អបជ បានយោងទៅតាមសេចក្តីសំរេចពីមុនរបស់ខ្លួននៅថ្ងៃទី២០ ឧសភា ២០០៨ ហើយបានបញ្ជាក់មតិយល់ឃើញរបស់ខ្លួនដោយយោងតាមវិធាន ៧៧(១០) ដែលបានចែងថា នៅ អបជ បន្ទាប់ពីអ្នកធ្វើរបាយការណ៍បានអានរបាយការណ៍របស់ពួកគេរួចហើយ, *"... មេធាវីតំណាងភាគីនីមួយៗ អាចបង្ហាញនូវសេចក្តីសង្ខេបរបស់ខ្លួន"*។

១៥. នៅថ្ងៃទី ០១ កក្កដា ២០០៨, បន្ទាប់ពីមានសេចក្តីសំរេចចិត្តដូចដែលបានចែងខាងលើ អ្នកដាក់ពាក្យស្នើសុំ បានបណ្តេញមេធាវីរបស់ខ្លួន ហើយជំរាប អបជ ថា ខ្លួនលែងមានតំណាងតាមផ្លូវច្បាប់ ទៀតហើយ ហើយស្នើសុំអនុញ្ញាតថ្លែងប្រាស្រ័យដោយខ្លួនគាត់ផ្ទាល់រយៈពេល ១០ នាទី (ជាពេលកំណត់ដែល អបជ ផ្តល់ឱ្យទៅភាគដើមបណ្តឹងរដ្ឋប្បវេណី) ហើយនិយាយអំពីប្រធានបទពាក់ពន្ធ័នឹងគោលការណ៍ ne bis in

---

[3] សេចក្តីសំរេចស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្នករណីលោក នួន ជា, អបជ, ថ្ងៃទី២០ មីនា ២០០៨, ព្រែ០០១៧២៨៨៦

[4]

[5]

idem ។ អបជ ក៏បានចេញសេចក្តីសំរេចមួយទៀត[6] (**«សេចក្តីសំរេចអំពីសិទ្ធិរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានការតំណាងស្របច្បាប់»**), ហើយបដិសេធទៅលើសំណើសុំទាំងឡាយរបស់ភាគី ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់ក្នុងតុលាការ។ អបជ បានយោងសេចក្តីសំរេចនេះទៅតាមវិធាន **៧៧**(១០) ម្តងទៀត។

១៦. ចៅក្រម រ៉ូវ៉ាន់ ដោននីង បានសរសេរ អំពីការមិនយល់ស្របរបស់គាត់ចំពោះបញ្ហានេះ ហើយបង្ហាញពីទស្សនៈរបស់គាត់ថា អ្នកដាក់ពាក្យស្នើសុំ គួរតែទទួលបានសិទ្ធិថ្លែងប្រាស្រ័យ ដោយផ្ទាល់នៅ ក្នុងតុលាការដោយខ្លួនឯង។ គាត់បានធ្វើការកត់សំគាល់ឃើញទៀតថា មានភាពមិនស្របគ្នារវាងវិធាន២៣ (ការផ្តល់សិទ្ធិឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញខ្លួន) និង វិធាន **៧៧**(១០) (ការដាក់កំរិតទៅលើការ ធ្វើសង្កេតរបស់ ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អបជ ជូនទៅ «មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី» វិញ)។ គាត់ធ្វើការបញ្ជាក់បន្តទៀតថា *«ផលប៉ះពាល់ដែលអាច កើតឡើងដោយសារសេចក្តីសំរេចចិត្តនៅក្នុងបញ្ហានេះ អាចជាការបញ្ចប់នូវសិទ្ធិរបស់ខាងក្នុងការលើកអំណះ អំណាងតទល់នឹងជនត្រូវចោទ តាមវិធាន ២៣(១)(ខ), ហើយជាលទ្ធផល បើអនុលោមទៅតាមគោលការណ៍មូលដ្ឋាន នៃវិធាន ២១(១)(ក)នោះ វានឹងក្លាយទៅជារឿងអយុត្តិធម៌ ក្នុងការដែលមិនអនុញ្ញាតិឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី បានថ្លែងប្រាស្រ័យនៅក្នុងតុលាការ»*។

១៧. នៅថ្ងៃទី០២ កក្កដា ២០០៨ អ្នកដាក់ពាក្យស្នើសុំបានដាក់ពាក្យស្នើសុំជាភាសាអង់គ្លេសជូនទៅ អបជ សុំឱ្យមានធ្វើការពិចារណាឡើងវិញទៅលើសេចក្តីសំរេចស្តីពីសិទ្ធិរបស់ភាគី ដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្មានការតំណាងតាមផ្លូវច្បាប់ (**«ការដាក់ពាក្យសុំឱ្យមានការពិចារណាឡើងវិញ»**) ក្នុងកំឡុងពេល សវនាការករណីលោក អៀង សារី។ ពាក្យស្នើសុំនោះត្រូវបានដាក់ជូនដោយមានសុពលភាពត្រឹមត្រូវ នៅថ្ងៃទី ០៤ កក្កដា ២០០៨ យោងទៅតាមពាក្យស្នើសុំជាភាសាខ្មែរដែលផ្ញើជូន អបជ កាលពីថ្ងៃទី០៣ កក្កដា។ ពាក្យស្នើសុំនោះបាន បញ្ជាក់ថា នៅក្នុងលិខិតផ្តល់សិទ្ធិ អ្នកដាក់ពាក្យសុំ បានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេត ដោយមុតមាំថារូបគាត់ចង់ការពារខ្លួនគាត់ដោយខ្លួនឯង រីមានមេធាវីការពារគាត់ ដូចនេះ ការណ៍ទាំងនេះនៅតែរក្សាសិទ្ធិពេញលេញរបស់គាត់ក្នុងការ ថ្លែងប្រាស្រ័យក្នុងតុលាការដោយខ្លួនគាត់ផ្ទាល់។

១៨. អ្នកដាក់ពាក្យសុំរូបនេះគឺជាភាគី ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានបំណង តំណាងឱ្យក្រុមអ្នកកំព្រា។ រូបគាត់បាននិយាយយ៉ាងទូលំទូលាយ (តាមរយៈ ការសំភាសន៍ អត្ថបទក្នុងកាសែត កម្មវិធីវិទ្យុ វេទិកាផ្សេងៗ ។ល។) និងជាមួយប្រជាពលរដ្ឋខ្មែរសាមញ្ញទូទាំងប្រទេស។ រូបគាត់បានទទួលការចាប់ អារម្មណ៍ ពីមនុស្ស

6

00204553

C22/I/62

ជាច្រើនដែលនឹងអាចនឹងក្លាយទៅជាអ្នក ដែលស្ថិតនៅក្រោមការ តំណាងរបស់ គាត់នៅក្នុង ក្រុមអ្នកកំព្រានេះ។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យសុំរូបនេះ បានរៀបចំសិក្ខាសាលាដែល មានរយៈពេលមួយថ្ងៃ និងកន្លះថ្ងៃ សំរាប់ក្រុមអ្នកកំព្រានេះពាសពេញប្រទេសកម្ពុជា ដោយចាប់ផ្តើមដំបូង នៅទីក្រុងភ្នំពេញនាថ្ងៃទី១៩ មេសា, នៅកោះកុង ថ្ងៃទី០៧ មិថុនា, និងនៅក្នុងពេលអនាគតខាងមុខ បន្ទាប់ ពីការរៀបចំវេទិកាសាធារណៈនិមួយៗរបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ស្តីពី «យុត្តិធម៌ និងការបង្រួបបង្រួម ជាតិ»។ វេទិកាទាំងនេះនឹងត្រូវរៀបចំឡើងនៅតាកែវ ថ្ងៃទី០១ សីហា, នៅកំពង់ចាម ថ្ងៃទី ៣០ សីហា, នៅប៉ៃលិន និងបាត់ដំបង ថ្ងៃទី ១៨ និង ១៩ កក្កដា និងជាបន្តបន្ទាប់ទៀត។ អ្នកដាក់ពាក្យសុំក៏មានគំរោង រៀបចំសិក្ខាសាលា នៅពេលដែលត្រូវធ្វើដំណើរទៅសហរដ្ឋអាមេរិច ក្នុងខែសីហា ២០០៨ ហើយសង្ឃឹមថា នឹងរៀបចំនៅប្រទេស អូស្ត្រាលី និងបារាំងនៅចុងឆ្នាំនេះ និងនៅដើមឆ្នាំក្រោយ។

១៩. អ្នកដាក់ពាក្យសុំ គ្រោងឱ្យមានជនរងគ្រោះពី ៥០ ទៅ ១០០នាក់ នៅក្រោមការតំណាងរបស់គាត់នៅក្នុងក្រុមអ្នកកំព្រា។

## III. ច្បាប់ដែលពាក់ព័ន្ធ

### *ក. វិធានផ្ទៃក្នុងរបស់ អវតក*

២០. **<u>វិធាន២១(១) របស់ អវតក</u>**

ច្បាប់របស់ អវតក ដែលបានចូលជាធរមាន វិធានផ្ទៃក្នុង សេចក្តីណែនាំនៃការអនុវត្តន៍ និងបទបញ្ញត្តិរដ្ឋបាល នឹងត្រូវបានបកស្រាយ ដើម្បីការពារផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវបានចោទ ជនជាប់ចោទ និង ជនរងគ្រោះ ជានិច្ច ។

- វិធាន ២១(១)(ក) ដំណើរការនិតិវិធី អវតក ត្រូវមានយុត្តិធម៌ និង មានការតតាំងគ្នា ហើយរក្សាតុល្យភាពរវាងសិទ្ធិ របស់ភាគីទាំងអស់
- ២១(១)(គ) អវតក ត្រូវតែធានាថាសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានគោរព នៅក្នុងកំឡុងពេលដំណើរការនីតិវិធី ទាំងស្រុង

២១. **<u>វិធាន ២៣ របស់ អវតក</u>**

- ២៣(១) គោលបំណងនៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អវតក គឺដើម្បី :

(ក) ចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ

ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នៅក្នុង វង្វង់យុត្តាធិការរបស់ អវតក ...

(ខ) អនុញ្ញាតអោយជនរងគ្រោះស្វែងរកសំណងជម្ងឺចិត្តជារួម និងសំណងសីលធម៌

- ២៣(៦)(ក) នៅពេលបានចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះក្លាយជាភាគីមួយនៅក្នុងដំណើរ ការនីតិវិធីព្រហ្មទណ្ឌ

- ២៣(៧) ... ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំអោយមេធាវីជាតិ រឺ មេធាវីបរទេស

ណាម្នាក់ តំណាងអោយខ្លួន

២២. **វិធាន ៧៧(១០)**

បន្ទាប់ពីអ្នកធ្វើរបាយការណ៍ បានអានរបាយការណ៍របស់ពួកគេចប់ សហព្រះរាជអាជ្ញា និងមេធាវី សំរាប់ភាគី ទាំងពីរអាចនឹងបង្ហាញជូននូវការថ្លែងសង្ខេប។

***ខ. សេចក្តីសំរេច និងសេចក្តីណែនាំរបស់ អង្គបុរេជំនុំជំរះ***

២៣. **អង្គបុរេជំនុំជំរះ នៅថ្ងៃទី២០ មិនា ២០០៨ របស់ អវតក : សេចក្តីសំរេចលើ ការចូលរួមរបស់ ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការប្តឹងជំទាស់ការឃុំខ្លួនបណ្តោះអាសន្ន**

(៣៦) អង្គបុរេជំនុំជំរះ យល់ឃើញថា អត្ថបទក្នុងវិធាន (២៣)(១)(ក) បានចែងច្បាស់ថា ដើមបណ្តឹង រដ្ឋប្បវេណីអាចចូលរួមនៅក្នុងគ្រប់ដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់ ដែលរួមទាំងនីតិវិធី ដែលទាក់ទង ទៅនឹងការប្តឹងជំទាស់ចំពោះការឃុំខ្លួនបណ្តោះអាសន្ននៅចំពោះ មុខអង្គបុរេជំនុំជំរះ ។

(៣៧) អង្គបុរេជំនុំជំរះ កត់សំគាល់ឃើញថាការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធី គឺជាការ ទទួលស្គាល់នូវការស្វែងរកការផ្សះផ្សាជាតិដូចដែលបានចែងស្រាប់។

C22/I/62

(៣៨) នៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌ, មាន ៤ មួយនៅក្នុងមាត្រា ២៥៩ និង ២៦០ ដែលបានចែង ឱ្យភាគីដើមបណ្តឹង រដ្ឋប្បវេណី មានភាពជាប់ពាក់ព័ន្ធ ក្នុងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាឃុំខ្លួន។ តាមការបក ស្រាយវិធាន ២៣(១) ដោយយោងទៅលើ ក្រមនីតិវិធីព្រហ្មទណ្ឌ មានន័យថាការ សរសេរនោះ បានប្រមើលមើលទុកជាមុន រួចមកហើយពីការ ចូលរួមរបស់ ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកំឡុងនីតិវិធី អ.វ.ត.ក, ដោយរួមបញ្ចូល ទាំងការប្តឹងជំទាស់តទល់នឹងដីកាឃុំខ្លួន បណ្តោះអាសន្នផងដែរ។

២៤. <u>ថ្ងៃទី២០ មិថុនា ២០០៨ អង្គបុរេជំនុំជំរះ របស់ អវតក : សេចក្តីសំរេច អំពី ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការប្តឹងជំទាស់ការឃុំខ្លួនបណ្តោះអាសន្ន</u>

(១) អវតក យល់ឃើញថា ដើម្បីជាប្រយោជន៍ចំពោះការធានាចំពោះដំណើរការនីតិវិធីឆាប់រហ័ស និងឯកសារសុំការព្រមព្រៀងដែលពាក់ព័ន្ធ និងដើម្បីចៀសវាងការរំខានដល់សវនាការ ...

២៥. <u>ថ្ងៃទី១ កក្កដា ២០០៨ សេចក្តីសំរេចរបស់អង្គបុរេជំនុំជំរះ ស្តីពីអង្គហេតុបឋម ដែលបានលើកឡើងដោយមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការប្តឹងជំទាស់របស់ លោក អៀង សារី</u>

(៥) ដោយពាក់ព័ន្ធជាមួយបញ្ហាយុត្តាធិការ អង្គបុរេជំនុំជំរះ ពិចារណាថា ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ដោយផ្ទាល់ ដែលដាច់ដោយឡែកពីផលប្រយោជន៍នៃភាគីដើមចោទ។ ប្រសិនបើអង្គបុរេជំនុំជំរះ ត្រូវធ្វើការសំរេចថាគ្មានសិទ្ធិចាប់ផ្តើមបណ្តឹងព្រហ្មទណ្ឌ ប្រឆាំងទល់នឹងជនដែលត្រូវចោទទេនោះ លទ្ធផលអាចថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសល់លទ្ធភាព ដើម្បីទាមទារសំណងជម្ងឺចិត្ត ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឡើយ។

២៦. <u>ថ្ងៃទី០៣ កក្កដា, សេចក្តីសំរេចចិត្តផ្ទាល់មាត់របស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី០១ កក្កដា ស្តីពីសំណូមពររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់នៅចំពោះមុខតុលាការ :</u>

(៣) អបជ យល់ឃើញថាភាគីដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវទទួលបានការអនុញ្ញាតិឱ្យថ្លែងប្រាស្រ័យដោយផ្ទាល់ទេ។ ប្រព័ន្ធនៅក្នុងវិធានផ្ទៃក្នុងមានចែងច្បាស់ណាស់។ ៤ ជាក់លាក់មួយចំនួនមាននៅក្នុងវិធានផ្ទៃក្នុង សំរាប់ដំណាក់កាលបុរេជំនុំជម្រះនេះ ស្តីពីភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ។ វិធាន ៧៧(១០) បានបង្ហាប់ថា មានតែមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុណ្ណោះដែលមានសិទ្ធិក្នុងការធ្វើថ្លែងសង្ខេបផ្ទាល់មាត់ នៅក្នុងកំឡុងពេលបណ្តឹងឧទ្ធរណ៍អង្គបុរេជំនុំជម្រះ។

00204556

C22/I/62

២៧. <u>ទស្សនៈជំទាស់របស់ចៅក្រម រ៉ូវ៉ាន់ ដោននីង (Rowan Downing)</u> :

៣. *យើងខ្ញុំត្រូវបានគេប្រាប់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី បានបណ្តេញមេធាវីរបស់នាង ដូច្នេះ ហើយនាងមិនមានតំណាងស្របច្បាប់ទៀតទេ នៅចំពោះមុខ អង្គបុរេជំនុំជម្រះ។ ខ្ញុំមានបំណងរៀបចំ ផ្តល់សិទ្ធិដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងឱកាសជាពិសេសមួយនេះ ដើម្បីអោយនាងបានបង្ហាញខ្លួន និងថ្លែងប្រាស្រ័យស្តីពីបញ្ហាយុត្តាធិការនៅចំពោះមុខអង្គបុរេ ថ្វីត្បិតតែមានការដាក់កម្រិត ដែលគេយល់ឃើញនៅក្នុងវិធាន ៧៧(១០) ក៏ដោយ។ ខ្ញុំលើកឡើងបែបនេះ ដោយឈរលើមូលដ្ឋានថា ផលប៉ះពាល់ដែលអាចកើតឡើងដោយសារសេចក្តីសំរេចចិត្តនៅក្នុងបញ្ហានេះ អាចជាការបញ្ចប់នូវសិទ្ធិរបស់នាងក្នុងការលើកអំណះអំណាងតទល់នឹងជនត្រូវចោទ តាមវិធាន ២៣(១)(ខ)។*

៤. *ជាលទ្ធផល តាមទស្សនៈរបស់ខ្ញុំ បើអនុលោមទៅតាមគោលការណ៍មូលដ្ឋាន នៃវិធាន ២១(១)(ក)នោះ វានឹងក្លាយទៅជារឿងអយុត្តិធម៌ ក្នុងការដែលមិនអនុញ្ញាតិឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងប្រាស្រ័យនៅក្នុងតុលាការ។*

*គ. ច្បាប់កម្ពុជា*

២៨. **បុព្វកថានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក**

... អវតក បានអនុម័តវិធានផ្ទៃក្នុងខាងក្រោមនេះ ក្នុងគោលបំណងបញ្ចូលនីតិវិធីកម្ពុជាដែលអាចអនុវត្តបាន សំរាប់ដំណើរការរឿងក្តីនៅចំពោះមុខ អវតក ...

២៩. <u>**ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ផ្នែកទី៣ : ការស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី, មាត្រា ១៥០**</u>

ភាគីដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានជំនួយពីមេធាវី។

> ... ចៅក្រមស៊ើបអង្កេត អាចសំភាសន៍ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំចាំបាច់កោះហៅមេធាវី ប្រសិនបើភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះ បោះបង់សិទ្ធិដោយអោយមានវត្តមានមេធាវីរបស់ខ្លួន។

៣០. <u>**ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៥៩:**</u> ភាគីនិងមេធាវីរបស់គេ អាចដាក់សារណារបស់ខ្លួនទៅកាន់ស្មៀនតុលាការ។ ភាគីនិងមេធាវីទាំងអស់ ត្រូវបានអនុញ្ញាតិឱ្យអោយដាក់សារណារបស់ខ្លួនរហូតដល់ពេលចាប់ផ្តើមដំណើរការសវនាការ។

៣១. <u>ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៦០:</u> អង្គស៊ើបអង្កេត អាចកោះហៅ ភាគីទាំងអស់ ... ឱ្យបង្ហាញខ្លួនជាបុគ្គលផ្ទាល់។

## IV. សេចក្តីសំអាង

៣២. យើងសូមថ្លែងសេចក្តីថាអ្នកដាក់ពាក្យ ត្រូវទទួលការអនុញ្ញាតិឱ្យថ្លែងប្រាស្រ័យនៅក្នុងតុលាការដោយខ្លួនឯង។ ការណ៍នេះស្របទៅនឹងវិធាន ២៣ និងគោលបំណងជាទូទៅដែលបានចែងនៅក្នុងវិធាន ២១(១)(ក) ហើយស្របទៅនឹងការយល់ដោយផ្ទាល់របស់តុលាការអំពីសារៈសំខាន់នៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានបញ្ជាក់នៅក្នុង*សេចក្តីសំរេចស្តីពីការចូលរួមរបស់ភាគី ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន* ចុះថ្ងៃទី ២០ មីនា ២០០៨។ លើសពីនេះទៅទៀតច្បាប់កម្ពុជា ដែលមានតួនាទីជាមគ្គុទេសក៍សំរាប់តុលាការនៅក្នុងបញ្ហានីតិវិធី ក៏បានអនុញ្ញាតិអោយមានភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចូលរួមដោយមិនចាំបាច់មានតំណាង។ ទីបញ្ចប់ សំរាប់ករណីពិសេសនេះ ដែលគេបានអនុញ្ញាតិឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសច្រើនជាងមួយដងនៅ ក្នុងការថ្លែងប្រាស្រ័យ ហើយពេលនេះមិនបានទទួលការផលប្រយោជន៍ពីមេធាវីទៀតនោះ វារឹតតែធ្វើឱ្យកាន់តែមានភាពសមស្របជាពិសេសក្នុងការអនុញ្ញាតិឱ្យមានការចូលរួមនោះ។ នៅពេលថ្លែងប្រាស្រ័យពីបញ្ហាអង្គហេតុនិងអង្គច្បាប់ដ៏ម៉ត់ចត់នោះ សំឡេងផ្ទាល់របស់ ភាគីដើមបណ្តឹងរដ្ឋប្ប វេណី នឹងមានវិសាលភាពផ្សេងខុសពីមេធាវី របស់ខ្លួន។ នៅក្នុងស្ថានភាព ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានការទទួលស្គាល់នេះ មិនមានការតំណាង, យើងសូមធ្វើញត្តិដោយ សេចក្តីគោរពជូនចំពោះតុលាការ សូមឱ្យធ្វើការពិចារណាឡើងវិញ ចំពោះ សេចក្តីសំរេច បដិសេធសិទ្ធិរបស់ ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យក្នុងតុលាការ កាលពីថ្ងៃទី ០១ កក្កដា ២០០៨។

៣៣. **<u>វិធាន ៧៧(១០)ត្រូវតែទទួលបានការបកស្រាយដោយយោងវិធាន ២៣(១), វិធាន ២១(១)(ក), គោលបំណងនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដូចបានចែងនៅក្នុង*សេចក្តីសំរេចចិត្ត ស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន កាលពីថ្ងៃទី ២០ មីនា ២០០៨*</u>**

៣៤. តុលាការបានយោងសេចក្តីសំរេចចិត្តក្នុងការដកអ្នកស្នើសុំចេញពីការចូលរួមនៅក្នុងអង្គបុរេជំនុំជម្រះតាមវិធាន ៧៧(១០) ដែលបានចែងថា «សហព្រះរាជអាជ្ញានិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចបង្ហាញសារណាអង្កេត»។ តុលាការបានបកស្រាយចំណុចនេះថា *មានតែ* សហព្រះរាជអាជ្ញា និងមេធាវីទេដែលអាច

ថ្លែងប្រាស្រ័យបាន។ តែទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំសូមធ្វើសេចក្ដីថ្លែងថា ដោយយោងទៅលើមាត្រាផ្សេងៗទៀតនៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជាសេចក្ដីសំរេចចិត្តផ្ទាល់របស់តុលាការស្ដីពីការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណាក់ការបុរេជំនុំជម្រះ, យោងទៅតាមវិធាន ៧៧(១០) គួរតែទទួលបានការបកស្រាយក្នុងលក្ខណៈទូលំទូលាយដោយបញ្ចូលភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួនផងដែរ។ ហើយការណ៍នេះ មានភាពស្របគ្នាទៅនឹងដំណើរការរបស់តុលាការនៅក្នុង *សេចក្ដីសំរេចស្ដីពីការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន* ចុះថ្ងៃទី ២០ មីនា ២០០៨ ដែលរកឃើញថាភាគីដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិចូលរួមក្នុងសវនាការឃុំខ្លួនបណ្ដោះអាសន្ននានា ទោះបីជាមិនមានអត្ថបទជាក់ស្ដែងក្នុងការចែងពីសិទ្ធិនេះក៏ដោយ។ តុលាការបានរកឃើញថា ទោះជាយ៉ាងណាក៏ដោយ សិទ្ធិនេះពិតជាមាន តាមរយៈការបកស្រាយវិធាន ២៣(១) ដោយយោងទៅលើគោលបំណងរបស់ អ.វ.ត.ក, ដោយរាប់បញ្ចូលទាំងការផ្សះផ្សាជាតិ, ក៏ដូចជាការអនុវត្តនៅក្នុងស្រុកនិងក្នុងឆាកអន្តរជាតិ។

៣៥. យើងខ្ញុំសូមឱ្យតុលាការប្រកាន់យកវិធីសាស្ត្រទូលំទូលាយនិងស្របតាមបរិបទ ក្នុងការបកស្រាយនៅក្នុងករណីនេះផងដែរ។ ដូចដែលតុលាការផ្ទាល់បានបញ្ជាក់ដោយប្រយោលផងដែរ នៅក្នុង *សេចក្ដីសំរេចស្ដីពីការចូលរួមរបស់ភាគី ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួន បណ្ដោះអាសន្ន* ចុះថ្ងៃទី ២០ មីនា ២០០៨ (កថាខណ្ឌ ៣៦) នោះ, វិធាន ២៣(១) បានចែងថាភាគីដើមបណ្ដឹងរដ្ឋប្បវេណី «មានសិទ្ធិយ៉ាងសកម្មក្នុងការចូលរួមចាប់តាំងពីដំណាក់កាលស៊ើបអង្កេតនៃនីតិវិធីទៅ»។ [សេចក្ដីសំរេចថ្ងៃទី ២០ មីនា ២០០៨, កថាខណ្ឌ ៣៦] *សេចក្ដីសំរេចនោះ* បានបន្តក្នុងការដកស្រង់សេចក្ដីអំពីការការគាំទ្រទាំងថ្នាក់ជាតិ និងអន្តរជាតិសំរាប់សំណើនេះ។ រាល់ហេតុផលដែលផ្ដល់ដោយតុលាការនៅក្នុងសេចក្ដីសំរេចចិត្តនេះ អាចអនុវត្តបានដោយស្មើភាពគ្នាចំពោះករណីដែលកំពុងកើតឡើងនេះ។ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងការពិភាក្សានេះ មិនមានការតំណាងនិងមិនមានមធ្យោបាយក្នុងការអះអាងការពារ សិទ្ធិរបស់ខ្លួនក្នុងនាមជា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយ ក្នុងការចូលរួមនៅក្នុងដំណាក់កាលបុរេជំនុំជម្រះនេះទេ។ ដូចដែលគំនិត ជំទាស់របស់ចៅក្រម ដោននីង បានថ្លែងសេចក្ដីសំអាងថា វាជាការប្រថុយនឹងគ្រោះថ្នាក់មួយដែលថា សិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការលើកអំណះសំអាងតទល់ជាមួយជនត្រូវចោទ អាចត្រូវបានលប់បំបាត់ ប្រសិនបើភាគីដើមបណ្ដឹងរដ្ឋប្បវេណីនោះ មិនត្រូវបានគេអនុញ្ញាតិឱ្យចូលរួមនៅ ក្នុងដំណាក់កាលបុរេជំនុំជម្រះនេះ។ សរុបសេចក្ដីមក យើងខ្ញុំសូមថ្លែងសេចក្ដីថា ការបដិសេធសិទ្ធិរបស់ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងសវនាការបុរេជំនុំជម្រះនេះ ផ្ទុយទៅនឹងអត្ថន័យនៅក្នុងវិធាន ២៣(១) ហើយមិនស្របទៅនឹង សេចក្ដីសំរេចផ្ទាល់របស់តុលាការស្ដីពីការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី។

៣៦. បន្ថែមទៅលើការផ្ទុយពីវិធាន ២៣(១)នេះ, ការបដិសេធសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យនៅក្នុងតុលាការនេះ ក៏បង្ហាញនូវផលវិបាកផងដែរទាក់ទងទៅនឹងវិធាន ២១(១)(ក) ដែលផ្តល់នូវការធានាពីភាពស្មើគ្នា និងតុល្យភាព រវាងសិទ្ធិរបស់ ភាគីទាំងអស់។ ប្រសិនបើ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្មានតំណាង ត្រូវគេបដិសេធ សិទ្ធិមិនឱ្យចូលរួមនោះ វាមានន័យថាជាការ ដាក់ឱ្យភាគីនេះទទួលបាននូវគុណវិបត្តិដ៏ធ្ងន់ធ្ងរ ប្រៀបទៅនឹងភាគីផ្សេងទៀត ហើយវាជារឿងអយុត្តិធម៌មួយ។ ការបញ្ចប់សិទ្ធិដែលអាចកើតមានឡើងបាន ក្រោមវិធាន ២៣(១) ក្នុងការលើកអំណះអំណាងតទល់នឹងជន ត្រូវចោទនេះ គឺគ្រាន់តែជាភាពអយុត្តិធម៌មួយដែលកើតចេញមកពីការបដិសេធសិទ្ធិរបស់ភាគីភាគីដើមបណ្តឹង រដ្ឋប្បវេណីក្នុងការចូលរួម។ ផលវិបាកមួយទៀត ដែលជាការពិតនោះ គឺអាចជាការបង្ខំឱ្យភាគីភាគីដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតស្វែងរកការតំណាងផ្នែកច្បាប់ ដែលករណីនេះ វាមិនត្រឹមតែផ្ទុយទៅនឹងអត្ថបទក្នុងវិធាន ២៣(៧) ដែលផ្តល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានមេធាវី ប៉ុន្តែមិនបានបញ្ជាក់ថាវាជាតម្រូវការប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាការ បង្ខំឱ្យទទួលដ៏អយុត្តិធម៌ថែមទៀតផង។ មនុស្សពេញវ័យដែលមានសតិបញ្ញាពេញលេញ មិនគួរត្រូវបានគេបង្ខំឱ្យទទួលយកការតំណាង ក្នុង គោលបំណងដើម្បីអះអាងការពារសិទ្ធិជាមូលដ្ឋានរបស់ខ្លួនដើម្បីចូលរួមក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី នោះទេ។ តុលាការបានយល់ថាភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួមនៅក្នុងសវនាការបុរេជំនុំ ជម្រះទាំងឡាយ។ វាមានភាពយុត្តិធម៌បានលុះត្រាតែ សិទ្ធិដូចគ្នានេះត្រូវបានគេផ្តល់ឱ្យទៅភាគីដើមបណ្តឹង រដ្ឋប្បវេណីដែលមិនទទួលបានផលប្រយោជន៍ពីមេធាវីរបស់ខ្លួន។

**៣៧. ការប្រៀបធៀបច្បាប់ក្នុងស្រុក**

៣៨. ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ៣៨ នៃ *សេចក្តីសំរេចស្តីពីការចូលរួមរបស់ភាគី ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន* ចុះថ្ងៃទី ២០ មីនា ២០០៨ របស់តុលាការ :

> នៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌ, មាន ២ មួយនៅក្នុងមាត្រា ២៥៩ និង ២៦០ ដែលបានចែងឱ្យភាគីដើមបណ្តឹង រដ្ឋប្បវេណី មានភាពជាប់ពាក់ព័ន្ធ ក្នុងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន។ តាមការបក ស្រាយវិធាន ២៣(១) ដោយយោងទៅលើ ក្រមនីតិវិធីព្រហ្មទណ្ឌ មានន័យថាការ សរសេរនោះ បានប្រមើលមើលទុកជាមុន រួចមកហើយពីការចូលរួមរបស់ ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកំឡុងនីតិវិធី អ.វ.ត.ក, ដោយរួមបញ្ចូល ទាំងការប្តឹងឧទ្ធរណ៍តទល់នឹងដីកាឃុំខ្លួន បណ្តោះអាសន្នផងដែរ។

៣៩. ជាងនេះទៅទៀត នៅក្នុងបុព្វកថានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងថា «អ.វ.ត.ក បាន អនុម័ត វិធានផ្ទៃក្នុងខាងក្រោមនេះ *ហើយដែលមានគោលបំណងបញ្ចូលនីតិវិធីកម្ពុជាដែលអាចអនុវត្តបាន សំរាប់នីតិវិធីរឿងក្តីនៅចំពោះមុខ អ.វ.ត.ក ...*»។

៤០. នៅក្នុងច្បាប់កម្ពុជា មិនមានកន្លែងណាមួយចែងថាភាគីដើមបណ្តឹងរដ្ឋប្បវេណី *ត្រូវការ* មេធាវីនោះ ទេ, គឺមានតែការចែងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី «អាចមានមេធាវីជាជំនួយ» (ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា, មាត្រា ១៥០)។ បន្ថែមលើនេះ មាត្រា ១៥០ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងថា «ចៅក្រមស៊ើបអង្កេត អាចសម្ភាសន៍ ភាគីដើមបណ្តឹង រដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីឡើយ ប្រសិនបើភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះ បោះបង់សិទ្ធិ របស់ខ្លួនជាដាច់ខាតដោយមានវត្តមានមេធាវី»។

៤១. ដោយសារតែ អ.វ.ត.ក បានធានាឱ្យមានការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង សវនាការ បុរេជំនុំជម្រះ និងមានគោលបំណងបញ្ចូលនីតិវិធីកម្ពុជា ទៅក្នុងនីតិវិធីរឿងក្តីចំពោះមុខ អ.វ.ត.ក នោះ, ការអនុវត្តច្បាប់ក្នុងស្រុកបានធានាយ៉ាងច្បាស់នូវសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួល បាននូវ ការតំណាង និងការចូលរួមដោយផ្ទាល់នៅក្នុងនីតិវិធីរឿងក្តី។

## ៤២. <u>**ក្តីបារម្ភពីនីតិវិធី ពាក់ព័ន្ធនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី**</u>

៤៣. នៅក្នុងសេចក្តីសំរេចថ្ងៃទី ២០ មីនា ២០០៨, អ.វ.ត.ក មានការយល់ឃើញប្រឆាំងនឹង ការចូលរួម ដោយផ្ទាល់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី «ក្នុងប្រយោជន៍ដើម្បីធានាឱ្យនីតិវិធីរឿងក្តីមានភាពឆាប់រហ័ស និងឱ្យមានសេចក្តីថ្លែងពាក់ព័ន្ធ ព្រមទាំងដើម្បីចៀសវាងការរំខានចំពោះសវនាការ ...»។ ក៏ប៉ុន្តែ ផល ប្រយោជន៍របស់តុលាការនៅក្នុងការរក្សាអោយមានសណ្តាប់ធ្នាប់នៅក្នុងសវនាការបុរេជំនុំជម្រះ អាច រឺ គួរតែ កើតមានឡើងដោយចុះសម្រុងរួមគ្នាជាមួយនិងសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យ ដោយផ្ទាល់។

៤៤. តុលាការធានាថា សវនាការបុរេជំនុំជម្រះទាំងឡាយ ត្រូវបានធ្វើឡើងក្នុងលក្ខណៈយុត្តិធម៌ និងមាន ប្រសិទ្ធភាព តាមរយៈការកំណត់ពេលវេលាស្មើគ្នាសំរាប់ការថ្លែងសេចក្តីផ្ទាល់មាត់ពីគ្រប់ភាគីទាំងអស់។ នៅ ខណៈពេលដែលភាគីត្រូវចោទ និងព្រះរាជអាជ្ញា បានចំណាយពេលវេលាដែលកំណត់ឱ្យក្នុងការបង្ហាញនូវ ករណីរបស់គេ តាមការជ្រើសរើសរបស់គេហើយនោះ, វាជារឿងដ៏សមហេតុផលមួយដែលភាគីដើមបណ្តឹង រដ្ឋប្បវេណីគួរតែអាចធ្វើបានដូចគ្នា។ ភាគីទាំងឡាយអាចជំទាស់ ហើយតុលាការមានសិទ្ធិបន្ថយនូវការថ្លែង

សេចក្តីច្រំដែល រឺមិនពាក់ព័ន្ធ ទោះជាភាគីណាកំពុងថ្លែងសេចក្តីក៏ដោយ។ ដោយសារតែនេះជាសមត្ថភាពរបស់តុលាការក្នុងការគ្រប់គ្រងនីតិវិធីរឿងក្តីនោះ, វាគួរតែមិនមានបញ្ហាទេ ទោះបីជាមេធាវី រឺក៏ ដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯង ថ្លែងប្រាស្រ័យនៅក្នុងកំឡុងពេលដែលបានកំណត់នោះ។

៤៥. លើសពីនេះទៅទៀត អ្នកដាក់ពាក្យស្នើសុំ បានថ្លែងប្រាស្រ័យនៅចំពោះមុខ តុលាការដោយផ្ទាល់នៅក្នុងសវនាការបុរេជំនុំជម្រះរបស់ អ.វ.ត.ក ក្នុងករណីលោក នួន ជា និងលោក ខៀវ សំផន រួចមកហើយ។ ការថ្លែងសេចក្តីរបស់គាត់ គឺមានភាពទាក់ទង, ដោយផ្ទាល់, ដោយសង្ខេប និងមិនដែលធ្វើឱ្យខូចប្រយោជន៍ដល់នីតិវិធីរឿងក្តីម្តងណាឡើយ។

៤៦. អ្នកដាក់ពាក្យស្នើសុំ មានការយល់ដឹងខ្ពស់ពីហានិភ័យនិងក្តីបារម្ភទាំងឡាយដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ នាងកំពុងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីធានាថា សំលេងនិងផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាង ស្របពេលនឹងការថែរក្សាឱ្យមានសេចក្តីសមរម្យថ្លៃថ្នូរ និងប្រសិទ្ធិភាព នៃសវនាការជំនុំជម្រះដោយយុត្តិធម៌។ ហេតុដូចនេះហើយទើបបានជា អ្នកដាក់ពាក្យស្នើសុំកំពុងធ្វើការដើម្បីបង្កើតជា ក្រុមអ្នកកំព្រា និងកំពុងជំរុញឱ្យអង្គការសង្គមស៊ីវិល និងភាគីដែលមាន ចំណាប់អារម្មណ៍ផ្សេងៗទៀត ឱ្យបង្កើតជាក្រុមផ្សេងៗគ្នា, ដូចដែលមានផ្តល់ជូននៅក្នុង ទម្រង់សំនុំបែបបទជនរងគ្រោះ (ដែលមានប្រអប់មួយសំរាប់គូសយក «មេធាវី» រឺ «អ្នកតំណាង»)។

៤៧. វាអាចជាជំនួយផងដែរសំរាប់តុលាការ ក្នុងការពិចារណាអំពីការត្រួតពិនិត្យចំនួនអ្នកតំណាងក្នុងការថ្លែងប្រាស្រ័យ ពីភាគីនិមួយៗ។ ដោយសារតែភាគីការពារក្តី និង ព្រះរាជអាជ្ញា មានមេធាវីពីររូបនៅក្នុងសាលសវនាការនោះ ប្រហែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណី គួរមានតំណាងសំរាប់ថ្លែងប្រាស្រ័យចំនួនពីរនាក់ដែរនៅថ្ងៃសវនាការនិមួយៗ។ ដូចនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវសំរេចជាផ្ទៃក្នុង ថាតើត្រូវធ្វើដូចម្តេច ហើយថាតើ អ្នកណានឹងត្រូវប្រើប្រាស់ពេលវេលាដែលផ្តល់ជូនសំរាប់ការថ្លែងប្រាស្រ័យនោះ ក្នុងការជួយបន្ថែមអនុភាពទៅលើសំឡេងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។

## V. សេចក្តីសន្និដ្ឋាន

៤៨. ភាគីដើមបណ្តឹងរដ្ឋប្បវេណី គួរតែត្រូវអនុញ្ញាតិឱ្យថ្លែងប្រាស្រ័យនៅចំពោះមុខតុលាការដោយផ្ទាល់។ ការណ៍នេះ ស្របទៅនឹងគោលបំណងនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី, រួមទាំងការផ្សះផ្សាជាតិផងដែរ, ដូចដែលមានចែងនៅក្នុងវិធាន ២១(១), វិធាន២៣ និងសេចក្តីសំរេចដោយផ្ទាល់របស់តុលាការកាលពីថ្ងៃទី២០ មីនា ២០០៨។ នៅពេលថ្លែងប្រាស្រ័យពីបញ្ហាអង្គហេតុនិងអង្គច្បាប់នោះ សំឡេងផ្ទាល់របស់

ភាគីដើមបណ្ដឹងរដ្ឋប្បវេណី នឹងមានវិសាលភាពផ្សេងខុសពីមេធាវីរបស់ខ្លួន។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យស្នើសុំ កំពុងស្វះស្វែងដើម្បីក្លាយទៅជាតំណាងរបស់ក្រុមអ្នកកំព្រា ហើយការបង្កើតជាក្រុមនេះ ត្រូវបានផ្ដល់ជូននៅក្នុងទម្រង់សំនុំបែបបទជនរងគ្រោះ និងជាការជួយជំរុញផ្នែករដ្ឋបាល។ ម្យ៉ាងវិញទៀត តាមច្បាប់ប្រទេសកម្ពុជា ដែលមានតួនាទីជាមគ្គុទេសក៍នីតិវិធី សំរាប់ អវតក នោះ មានន័យថាភាគីដើមបណ្ដឹងរដ្ឋប្បវេណី អាចចូលរួមដោយគ្មានជំនួយពីមេធាវីនៅក្នុងកំឡុងពេលគ្រប់ដំណាក់កាលនៃដំណើរការតុលាការ។ ជាទីបញ្ចប់ ផលប្រយោជន៍របស់តុលាការក្នុងការរក្សាសណ្ដាប់ធ្នាប់ អាចកើតឡើងរួមគ្នា ជាមួយនឹងការផ្ដល់សិទ្ធិឱ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងប្រាស្រ័យដោយផ្ទាល់។ ហេតុដូចនេះហើយ យើងខ្ញុំសូមសំណូមពរឱ្យតុលាការផ្ដល់ ដចេលាភតិរេ រលិថេ ទៅដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់។

00204563

C22/I/62

**BEFORE THE PRE-TRIAL CHAMBER**

**EXTRAORDINARY CHAMBERS IN THE COURTS OF CAMBODIA**

| | |
|---|---|
| **Case No:** | 002/19-09-2007-ECCC/OCIJ (PTC03) |
| **Filed to:** | Pre-Trial Chamber |
| **Date of Document:** | 17 July 2008 |
| **Party Filing:** | Civil Party |
| **Language:** | Khmer and English |
| **Type of Document:** | PUBLIC |

---

## APPLICATION FOR DECLARATIVE RELIEF FOR CIVIL PARTY TO SPEAK IN PERSON, NOT FOR RE-HEARING

---

**Respectfully Yours,**

**Theary C. SENG**
**Civil Party**

Phnom Penh
July 17, 2008